ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

០៨-០២-២០០៧ -ព្រះរាជក្រម នស/រកម/០២០៧/០១០ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៤ របស់អាស៊ានស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត ២២២៦

២. ព្រះរាជក្រឹត្យ

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨១ ស្តីពីការតែងតាំងមន្ត្រីរាជការ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ០២ រូប ២២៥៨

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨២ ស្តីពីការតែងតាំងលោក **លី ហួរ** ជាឧកញ៉ា ២២៥៩

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨៣ ស្តីពីការតែងតាំងឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា ២២៦០

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨៤ ស្តីពីការតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០២ នាក់នៃក្រសួង មហាផ្ទៃ ២២៦១

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨៥ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូននាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ចំនួន ៤៤៥ រូប ២២៦២

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨៦ ស្តីពីការតែងតាំងឯកឧត្តម **ហុង ថា** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើអនុរដ្ឋលេខាធិការ ២២៧១

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨៧ ស្តីពីការតែងតាំងឯកឧត្តម **គៀង សាវុធ** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ២២៧២

២២-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៨៨ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **សូ ខុនហ្វរ** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ២២៧៣

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៦-០២-២០០៧ -អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួម សំរាប់ការអនុវត្តនីគំរោងហិរញ្ញប្បទានសហប្រតិបត្តិការ ពីធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី ២២៧៤

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៦

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៧

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២២៧៩

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២២៨១

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៨០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២២៨៥

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៨១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២២៨៦

២៧-០២-២០០៧ -អនុក្រឹត្យលេខ ១៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៨៨

២. សេចក្តីសំរេច

២៦-០២-២០០៧ -សេចក្តីសំរេចលេខ ១០ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យដោះស្រាយការជីករណ្តៅដីនៅភូមិសាស្ត្ររាជធានីភ្នំពេញ ២២៩០

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៣-០១-២០០៧ -ប្រកាសលេខ ០០២ ប្រក.កសក ស្តីពីបញ្ជីកំរិតអតិបរិមានៃសំណល់ថ្នាំកសិកម្មក្នុងកសិផលមានដើមកំណើតពីរុក្ខជាតិ ២២៩៣

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាកឡាក មណ្ឌល គីរី អគិចឡ្សន៍ កៅស៊ូ** ២៣២៦

គ

៣០-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាម មើង អ៊ីមផត អិចផត** ២៣២៨

៣០-១១-២០០៦ -លិខិតបញ្ជាក់លេខ ៣០៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សីហានុវីល ស្ពេសល អ៊ីខននើមី ហ្សូន** ២៣៣០

០១-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចាន តំរ អ៊ី ឌីវេឡុបមេន** ២៣៣២

០១-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆៀន ឌូ ស៊ីឃ្យូរីធី អេឃ្វីបមេន ខមភេនី លីមីធីត** ២៣៣៤

០១-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តៀក ហ្វា កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ** ២៣៣៦

០១-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យេលឡូ ថៅវើរ** ២៣៣៨

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីរេស៊ាន ឌីវេឡុបមេន** ២៣៤០

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីអេឡូជីខល ម៉ាញ នីង ថេកណូឡូជី (ខេមបូឌា)** ២៣៤២

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ៉ាយ អិល ខមភេនី** ២៣៤៤

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រីន អេយើរ ប្រាយវេត អិលធីឌី** ២៣៤៦

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាល់តា អិលធីឌី** ២៣៤៨

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន យូនីតធី មេនផៅវ័រ ខូ អិលធីឌី** ២៣៥០

០៤-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៦៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាយជីង គ្រេឌីត ម៉ីហ្គិច អេសឌីអិន.ប៊ីអេចឌី** ២៣៥២

០៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជខស្ទឹខ** ២៣៥៤

០៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តួខ តួ** ២៣៥៦

០៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣០៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.ដាប់ប៊ែលយូ. អ៊ិនធើណេសិនណាល** ២៣៥៨

ព្រះរាជក្រម

នស/រកម/០២០៧/០១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៤ របស់អាស៊ានស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

2/3

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើពិធីសារទី ៤ របស់
អាស៊ានស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត

មាត្រា ១.-

អនុម័តយល់ព្រមលើពិធីសារទី ៤ របស់អាស៊ានស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត ដែលធ្វើនៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៧

នស/រកម.០២០២.០១៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា
ស៊ុន ចាន់ថុល

លេខៈ ៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
យ៉ុន ជីនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

ពិធីសារអាស៊ាន

ពិធីសារទី ៤

ស្តីពី

តម្រូវការ ផ្នែកបច្ចេកទេសរបស់យានយន្ត

TECHNICAL REQUIREMENTS OF VEHICLES

នាយកដ្ឋានផែនការ - មិថុនា ២០០២

PLANNING DEPARTMENT, JUNE 2002

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ......៧៤......សារាណ.ករ

សេចក្តីថ្លែងហេតុនៃ
សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រម លើពិធីសារអាស៊ាន
ស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្ត

ក- លំនាំដើម

នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៥ របស់រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១៤-១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានបានឯកភាពយល់ព្រម និងចុះហត្ថលេខា លើពិធីសារ និងកិច្ចព្រមព្រៀងចំនួន ៣ ដូចខាងក្រោម :

- ពិធីសារទី ៣ : ស្តីពីការកំណត់ប្រភេទ និងបរិមាណយានយន្តដឹកជញ្ជូនផ្លូវគោក
- ពិធីសារទី ៤ : ស្តីពីតម្រូវការបច្ចេកទេសរបស់យានយន្ត
- កិច្ចព្រមព្រៀងថ្នាក់រដ្ឋមន្ត្រី ស្តីពីការអភិវឌ្ឍបណ្តាញផ្លូវអាស៊ានហាយវេ

ពិធីសារទី ៤ នេះ ជាពិធីសារលំអិតផ្នែកបច្ចេកទេស សម្រាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីអំពីការសម្រួលការដឹកទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅខែ សីហា ឆ្នាំ ១៩៩៨ នៅទីក្រុងហាណូយ ប្រទេស វៀតណាម ...បជាកិច្ចព្រមព្រៀងមួយនៅក្នុងចំណោមកិច្ចព្រមព្រៀង និងពិធីសារទាំង ២៧ របស់អាស៊ានហើយ ដែលសភាជាតិបានផ្តល់ ...ាប័នទទួលស្គាល់រួចហើយ កាលពីឆ្នាំ ២០០០ កន្លងទៅ បន្ទាប់ពីកម្ពុជាបានចូលជាសមាជិកអាស៊ាន ។ កិច្ចព្រមព្រៀងនេះ តម្រូវឱ្យប្រទេសជាសមាជិកយល់ព្រម និងចុះហត្ថលេខាលើពិធីសារចំនួន ៩ ដែលលំអិតខាងបច្ចេកទេសសម្រាប់អនុវត្ត កិច្ចព្រមព្រៀង :

ពិធីសារទី ១ : ការកំណត់ទុកជាមុននៃផ្លូវ និងមធ្យោបាយ លើផ្លូវថ្នល់សម្រាប់សម្រួល ក្នុងការដឹកជញ្ជូនឆ្លងកាត់

ពិធីសារទី ២ : ការកំណត់ជាមុននៃប៉ុស្តិ៍ត្រួតពិនិត្យតាមព្រំដែន

ពិធីសារទី ៣ :ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត

ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រង ក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត

ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយប្តូរផ្លូវដែកទាំងឡាយ

ពិធីសារទី ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់

មានពិធីសារចំនួន ៣ ដែលបានចុះហត្ថលេខារួចហើយដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន

ពិធីសារទី ៣ : ប្រភេទ និងបរិមាណនៃយានយន្តតាមផ្លូវគោក (ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៤ : តម្រូវការខាងបច្ចេកទេសនៃយានយន្ត (ចុះហត្ថលេខានៅឆ្នាំ ១៩៩៩)

ពិធីសារទី ៩ : ទំនិញគ្រោះថ្នាក់ (ចុះហត្ថលេខាកាលពីឆ្នាំ ២០០២ និងកំពុងសុំសច្ចាប័នពីរដ្ឋសភាជាតិ)

មានពិធីសារចំនួន ០២ ទៀត បានចុះហត្ថលេខានៅចុងឆ្នាំ ២០០០ និងដើមឆ្នាំ ២០០១
ដោយក្រសួង ស្ថាប័នផ្សេងៗ :

<u>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</u>

- ពិធីសារទី ៥ : ផែនការអាស៊ាននៃការធានារ៉ាប់រង ក្នុងកាតព្វកិច្ចទទួលខុសត្រូវរបស់យានយន្ត (ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិ កាលពីឆ្នាំ ២០០២ កន្លងទៅ)

<u>ក្រសួងកសិកម្ម និងក្រសួងសុខាភិបាល</u>

- ពិធីសារទី ៨ : វិធានការអនាម័យ និងភូតគាមអនាម័យ (ពិធីសារនេះ បានផ្តល់សច្ចាប័នរួចហើយពីរដ្ឋសភាជាតិ កាលពីឆ្នាំ ២០០២ កន្លងទៅ)

មានពិធីសារ ៤ ទៀត ដែលពុំទាន់បានចុះហត្ថលេខា :

-ពិធីសារទី១: ការកំណត់ទុកជាមុនផ្លូវ និងមធ្យោបាយ លើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់។ បច្ចុប្បន្នពិធីសារនេះ បានឈានចូល ដល់ដំណាក់កាលឯកភាពគ្នា នឹងចុះហត្ថលេខានៅខែ វិច្ឆិកា ឆ្នាំ ២០០៥ ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី ១១ នៅទីក្រុងវៀងច័ន្ទប្រទេសឡាវ។

- ពិធីសារទី ៦ : ព្រំដែនផ្លូវដែក និងស្ថានីយប្តូរផ្លូវដែកទាំងឡាយ (ពិធីសារនេះនៅរង់ចាំចម្លើយជាចុងក្រោយពីប្រទេសសិង្ហបុរី និងអាចចុះហត្ថលេខាបាននៅឆ្នាំ ២០០៦ ខាងមុខ) រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិ

ប្រទានរួចហើយ ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះហត្ថលេខាកាលពីឆ្នាំ ២០០១ និង ២០០៤ កន្លងទៅ ។

- ពិធីសារ ២ : ការកំណត់ជាមុននៃប៉ុស្តិ៍តាមព្រំដែន
- ពិធីសារ ៧ : ប្រព័ន្ធគយសម្រាប់ការឆ្លងកាត់

ពិធីសារទាំង ២ នេះ ជាសមត្ថកិច្ចរបស់ស្ថាប័នគយ ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន ប៉ុន្តែត្រូវជាប់គាំងដោយពិធីសារទី១ : (ការកំណត់ទុកជាមុននៃផ្លូវ និងមធ្យោបាយលើផ្លូវផ្តល់សម្រាប់សម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់) ដែលពុំទាន់អាចចុះហត្ថលេខាបាន ។

ពិធីសារទី ៤ មាន ៨ មាត្រា និងឧបសម្ព័ន្ធ ៦ ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន ។

គោលបំណងនៃពិធីសារទី៤ គឺដើម្បីកំណត់ប្រភេទ និងបរិមាណយានយន្តសម្រាប់អនុវត្តក្នុងការសម្រួលការដឹកជញ្ជូនទំនិញឆ្លងកាត់ កំណត់កាតព្វកិច្ច ការរៀបចំស្ថាប័ន របស់ភាគីចុះកិច្ចសន្យា ឬប្រទេសជាសមាជិក និងការចូលរួមរបស់ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ ។

I- ខ្លឹមសារសង្ខេប និងចំណុចសំខាន់ៗ

- ពិធីសារបានកំណត់និយមន័យនៃពាក្យបច្ចេកទេសសំខាន់ៗ ដែលជាតម្រូវការក្នុងការត្រួតពិនិត្យបច្ចេកទេសយានយន្ត។ ពិធីសារក៏បានកំណត់ផងដែរ អំពីទំហំនៃការប្រតិបត្តិ និងកាតព្វកិច្ច ក្នុងការអនុវត្តពិធីសារ។ យានយន្តដឹកជញ្ជូនឆ្លងកាត់ត្រូវចុះបញ្ជីជាមួយគណៈកម្មាធិការជាតិសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់រៀងៗខ្លួន ភាគីនីមួយៗ ធានាថា យានយន្តដឹកជញ្ជូនឆ្លងកាត់ ត្រូវបំពេញទៅតាមលក្ខណបច្ចេកទេស ទំហំ (បណ្តោយ-ទទឹង-កម្ពស់)
- ទម្ងន់សរុប អតិបរិមា និងបន្ទុក កម្រិតស្តង់ដា នៃការបញ្ចេញផ្សែង និងចំណុចពាក់ព័ន្ធ ដែលមានចែងក្នុងពិធីសារនេះ។ ភាគីទាំងអស់ត្រូវគិតគូអំពីស្ថានភាព បច្ចុប្បន្នរបស់ផ្លូវ និងបញ្ជាក់អំពីការតាំងចិត្តរបស់គេ ដើម្បីធ្វើឱ្យប្រសើរឡើងនូវផ្លូវដឹកជញ្ជូន ដែលពួកគេបានកំណត់គ្នា និងដែលអាចធ្វើទៅបានតាមការខិតខំប្រឹងប្រែងរបស់ខ្លួនតម្រូវទៅតាមលក្ខណបច្ចេកទេសយានយន្ត ដូចក្នុងពិធីសារនេះ
- ត្រូវយកជាប់ខ្លួនជាប្រចាំឯកសារដូចជា វិញ្ញាបនប័ត្រចុះបញ្ជី (លក្ខណៈ និងកម្មសិទ្ធិយានយន្ត) សុពលភាពវិញ្ញាបនប័ត្រ ប័ណ្ណបញ្ជាក់ការធានារ៉ាប់រងភាគីទី ៣ កំណត់នៃការប្រគល់ ឬ បញ្ជីអ្នកដំណើរ ឬ បញ្ជីកញ្ចប់ទំនិញឯកសារគយឆ្លងកាត់ សម្រាប់ទំនិញ អាជ្ញាប័ណ្ណក្រុមហ៊ុនដឹកជញ្ជូន ។ល។

- ឯកសារណាមួយមិនមានសុពលភាពនឹងមិនទទួលស្គាល់សម្រាប់អនុវត្តដោយពិធីសារនេះទេ។ រាល់ឯកសារទាំងអស់ត្រូវភ្ជាប់ការបញ្ជាក់បកប្រែជាភាសាអង់គ្លេស ។ យានយន្តដឹកជញ្ជូនឆ្លងកាត់គ្រប់ពេលវេលាត្រូវមានបិទបង្ហាញផ្លាកសញ្ញាសម្គាល់ នៃការចុះបញ្ជីពីភាគីជាប្រទេសដើមរបស់ខ្លួន
- កិច្ចប្រជុំក្រុមមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ គឺជាអ្នកទទួលខុសត្រូវសម្របសម្រួល ត្រួតពិនិត្យ និងធ្វើរបាយការណ៍ទៀងទាត់អំពីភាពជឿនលឿន ក្នុងការអនុវត្តពិធីសារនេះ ជូនក្រុមប្រឹក្សាសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ថ្នាក់តំបន់របស់អាស៊ាន ដោយមានការជួយទ្រទ្រង់ខាងបច្ចេកទេស និងតាមរយៈលេខាធិការដ្ឋានអាស៊ាន
- ពិធីសារនេះបានគេចុះហត្ថលេខា និងតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកចែកផ្សព្វផ្សាយឱ្យបានរហ័សទៅគ្រប់ភាគី
- ពិធីសារនេះ និងឧបសម្ព័ន្ធរបស់វា គឺជាផ្នែកបញ្ចូលគ្នាជាមួយកិច្ចព្រមព្រៀង
- ពិធីសារនេះ ជាកម្មវត្ថុនៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា
- លិខិតុបករណ៍ នៃការធ្វើសច្ចាប័ន ឬការចូលត្រូវតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយយ៉ាងរហ័ស ទៅគ្រប់ភាគីចុះកិច្ចសន្យា
- ពិធីសារចូលជាធរមាននៅពេលលិខិតុបករណ៍ នៃការធ្វើសច្ចាប័ន ឬការសុំចូលពីគ្រប់ភាគី និងតម្កល់ទុកនៅលេខាធិការដ្ឋានអាស៊ាន
- វិសោធនកម្មនៃពិធីសារ និងឧបសម្ព័ន្ធរបស់វាអាចប្រព្រឹត្តទៅបាន តាមការព្រមព្រៀងពីគ្រប់ភាគីទាំងអស់ ។

អាស្រ័យដូចបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រម លើពិធីសារអាស៊ាន ស្តីពីតម្រូវការផ្នែកបច្ចេកទេសរបស់យានយន្តនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

ពិធីសារទី ៤
ស្តីពីតម្រូវការ ផ្នែកបច្ចេកទេសរបស់យានយន្ត

❖❖❖ ❖❖❖❖❖❖❖

រដ្ឋាភិបាល នៃប្រទេស ប៊្រុយណេ ដារូសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូណេស៊ី, សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ, ប្រទេសម៉ាឡេស៊ី, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម, គឺជារដ្ឋសមាជិក នៃសមាគមប្រជាជាតិ អាស៊ីភាគអាគ្នេយ៍ (ពីពេលនេះតទៅ ហៅកាត់ថា " ភាគីចុះកិច្ចសន្យា ")

រំលឹកឡើងវិញ ពីកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី 16-ធ្នូ- 1998 នៅទីក្រុងហាណូយ ប្រទេសវៀតណាម (តទៅហៅកាត់ថាកិច្ចព្រមព្រៀង) ។

ទទួលស្គាល់ថា ថាមាត្រា ១១ និង ២៩ របស់កិច្ចព្រមព្រៀង ចែងសំរាប់ការសំរេចចិត្តនូវការអនុវត្តន៍ពិធីសារទាំងឡាយដែលនឹងបង្កើតជាផ្នែករួមបញ្ចូលគ្នា របស់កិច្ចព្រមព្រៀង និងមាត្រាទាំងឡាយរបស់វា ។

រំលឹកឡើងវិញបន្ថែម នូវផែនការសកម្មភាព ទីក្រុងហាណូយ ដែលបានយល់ព្រមដោយបណ្តាប្រមុខរដ្ឋ និងរដ្ឋាភិបាលអាស៊ាន នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទិ ៦ នៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលចែងអោយធ្វើការប្រតិបត្តិ កិច្ចព្រមព្រៀងនៅឆ្នាំ ២០០០ ។

បច្ចុប្បន្នដោយហេតុដូចនោះ បណ្តាភាគីចុះកិច្ចសន្យា បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រាទី ១
និយមន័យ

សំរាបបំរើអោយគោលបំណង នៃពិធីសារនេះ :

ក- "Transit Transport/ការដឹកជញ្ជូនឆ្លងកាត់ " ត្រូវមានអត្ថន័យដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។

ខ- "RoadTransit Transport Vehicles/ រថយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោក " ត្រូវមានអត្ថន័យដូចដែលបានកំណត់នៅ ក្នុងពិធីសារទី ៣ ។

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

ឍ- " Protocol 3 / ពិធីសារទី ៣ " មានន័យថា ពិធីសារទី ៣ ស្តីពីប្រភេទនិងបរិមាណយានយន្តផ្លូវគោក អនុលោម ទៅតាមកិច្ចព្រមព្រៀង ។

ឃ- "Wheelbase/ ចំងាយចន្លោះភ្លៅនៃកង់រថយន្ត " មានន័យថា ចំងាយរវាង ខ្សែបន្ទាត់កណ្តាលនៃភ្លៅកង់មុខ (First Axle) និងចំនុចកណ្តាលរបស់ភ្លៅកង់ក្រោយផ្តុំគ្នារបស់រថយន្តរឹងគ្មានតំណដែលមានភ្លៅ ៣ ជួរ " Three Axle Rigid Motor Vehicle " ។

ង- " Maximum Permissible Gross Vehicle Weight / ទំងន់យានយន្តសរុបអតិបរិមា ដែលអាចអនុញ្ញាតអោយ " មានន័យថា ជាទំងន់អតិបរិមាដែលអនុញ្ញាតរបស់រថយន្ត ដោយគិតទាំងទំងន់អ្នកបើកបរ មនុស្សទាំងអស់ និងទំងន់ផ្ទុកសរុប ឬ បន្ទុកនៅលើរថយន្តដែលសង្កត់បញ្ជូន ទៅលើផ្លូវថ្នល់តាមរយៈកង់របស់វាទាំងអស់ ។

មាត្រាទី ២
វិសាលភាពនៃការអនុវត្តន៍

អនុលោមទៅតាមប្រការ ១១ នៃកិច្ចព្រមព្រៀង. ភាគីចុះកិច្ចសន្យាទាំងឡាយតាមរយៈនេះ យល់ព្រមធ្វើតាម (ឬ បំពេញតាម) បទប្បញ្ញត្តិទាំងឡាយ នៃពិធីសារនេះ ទៅលើយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ដែលចូលរួមក្នុងការដឹកជញ្ជូនឆ្លងកាត់ ។

មាត្រាទី ៣
ភារកិច្ច

១- ភាគីចុះកិច្ចសន្យាត្រូវធានាថា យានយន្តដឹកជញ្ជូនឆ្លងកាត់និមួយៗ ត្រូវតែបានគេចុះបញ្ជីជាមួយនឹង គណៈកម្មាធិការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់រៀងខ្លួនៗ (គជសដឆ) ដែលអ្នកប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ទាំងនោះបានចុះបញ្ជី ស្របទៅតាម ពិធីសារទី ៣ ។

២- ភាគីចុះកិច្ចសន្យា ត្រូវធានាថាយានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកនិមួយៗ បំពេញទៅតាមតំរូវការខាងបច្ចេកទេស ទៅតាមទំហំ(បណ្តោយ ទទឹង កំពស់)នៃយានយន្ត ទំងន់សរុបអតិបរិមា និងបន្ទុកកំរិតស្តង់ដារនៃការបញ្ចេញផ្សែង និងចំណុចពាក់ព័ន្ធទាំងឡាយដែលបានអធិប្បាយលំអិត នៅក្នុងពិធីសារនេះ ។

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

មាត្រាទី ៤
តម្រូវការខាងបច្ចេកទេសជាចាំបាច់

១- យានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោក ដោយបំពេញតាមពិធីសារនេះ មិនត្រូវបានគេអនុញ្ញាតអោយចូលរួមសំរាប់ការដឹកជញ្ជូនឆ្លងកាត់ទេ លើកលែងតែតំរូវការខាងបច្ចេកទេស ដូចខាងក្រោមនេះត្រូវបានគេបំពេញ :

ក- ទំហំយានយន្តអតិបរិមាពោលគឺ : (Maximum Vehicle Dimension)

ក-១ ប្រវែងបណ្តោយរថយន្តអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ A & B

ក-២ ប្រវែងទទឹងរថយន្តអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ C

ក-៣ កំពស់រថយន្តអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ D

ក-៤ " កន្ទុយក្រោយ " ដែលភាសាអង់គ្លេសហៅថា Rea Overhang (ROH) " ប្រវែងពីចំនុចកណ្តាលនៃចង្កោមភ្លៅកង់ក្រោយ ទៅចំនុចក្រោយបំផុតនៃកន្ទុយយាន " ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ E

ខ- ទំងន់សរុបអនុញ្ញាតអតិបរិមា ដូចដែលបានលំអិតក្នុងឧបសម្ព័ន្ធ F

គ- ស្តង់ដារ នៃការបញ្ចេញផ្សែងដូចខាងក្រោម (Emission Standards) :
ការបញ្ចេញឧស្ម័នចោល(ផ្សែង)៥០ % (អូប៉ាស៊ីធី (Opacity) ឬក៏ទៀនបញ្ឆេះ-ប៊ូស្ស៊ី (Bosh) ឬ ៥០ HSU និង

ឃ- តំរូវការពាក់ព័ន្ធផ្សេងៗ ដូចជា :

ឃ-១ ប្រសិទ្ធិភាពហ្វ្រាំង : 50% នៃទំងន់របស់ភ្លៅ និង

ឃ-២ ភាពរអិលចេញពីផ្លូវ : បូក (+) ឬ ដក (-) ៥ ម/គម

២- ភាគីចុះកិច្ចសន្យា យល់ព្រមដាក់កំរិតស្តង់ដារ តំរូវការបច្ចេកទេសខាងលើ សំរាប់ពិធីសារនេះ ប៉ុន្តែតំរូវការគិតគូរពិចារណា អំពីស្ថានភាពបច្ចុប្បន្នរបស់ផ្លូវ នៃបណ្តាប្រទេសសមាជិកមួយចំនួនវាត្រូវបានគេយល់ព្រមថាជាកិច្ចការព្រមព្រៀងចាំបាច់ ត្រូវបានរៀបចំឡើង ដើម្បីអោយមានការចូលរួមក្នុងការកត់ត្រា កែសំរួលពត៌មានដែលជាប់ពាក់ព័ន្ធ ក្នុងការកំណត់ផ្លូវដឹកជញ្ជូនជាដំណាក់ៗ រវាងបណ្តាប្រទេសជាសមាជិក និងសមស្រប

ទៅតាមយានយន្តតែប៉ុណ្ណោះ ដែលសមរម្យទៅតាមស្ថានភាពផ្លូវទាំងនោះនៅក្នុងដំណាក់កាលដំបូងទាំងឡាយ នៃការអនុវត្តន៍ ពិធីសារនេះ ។ នៅពេលជាមួយគ្នានេះ ភាគីចុះកិច្ចសន្យា ត្រូវបញ្ជាក់សំអាងអំពីការសំរេចចិត្ត របស់ពួកគេ ដើម្បីធ្វើអោយប្រសើរឡើងនូវផ្លូវដែលបានកំណត់របស់ពួកគេ ទៅតាមការខិតខំប្រឹងប្រែងដែល អាចធ្វើទៅបាន ដើម្បីតំរូវទៅតាមយានយន្តជាមួយ នឹងតំរូវការបច្ចេកទេសដូចខាងលើ ។

មាត្រាទី ៥

ឯកសារ

១- ឯកសារទាំងឡាយដូចខាងក្រោម ត្រូវបានគេយកជាប់តាមយានយន្តដឹកជញ្ជូនឆ្លងកាត់លើផ្លូវគោកមួយ នៅ គ្រប់ពេលវេលាទាំងអស់ នៅពេលដែលវាស្ថិតនៅក្នុងដែនដី នៃភាគីជាប់កិច្ចសន្យាជាប់ពាក់ព័ន្ធ ដែលការដឹក ជញ្ជូនឆ្លងកាត់ ធ្វើឡើងកាត់តាមទឹកដី នៃភាគីចុះកិច្ចសន្យានោះ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីយានយន្ត ដែលមានចុះលក្ខណៈពិសេសៗនៃយានយន្ត និងម្ចាស់កម្មសិទ្ធិ

ខ- សុពលភាពវិញ្ញាបនប័ត្រនៃការត្រួតពិនិត្យយានយន្ត

គ- ការបញ្ជាក់ធានារ៉ាប់រងទទួលខុសត្រូវនៃភាគីទី ៣ ទៅលើយានយន្ត

ឃ- កំណត់ការប្រគល់ / បញ្ជីអ្នកដំណើរ ឬ កញ្ចប់ទំនិញ

ង- ឯកសារគយឆ្លងកាត់ សំរាប់ទំនិញ និង

ច- អាជ្ញាប័ណ្ណក្រុមហ៊ុនដឹកជញ្ជូន

២- រាល់បណ្តាឯកសារដែលបានកត់សំគាល់ខាងលើ ត្រូវតែផល់អត្តិភាពសំរាប់ការត្រួតពិនិត្យនៅពេលមានសំណើរ ដោយអាជ្ញាធរពាក់ព័ន្ធទាំងឡាយ នៃភាគីជាប់កិច្ចសន្យា ដែលការដឹកជញ្ជូនឆ្លងកាត់ធ្វើឡើងកាត់តាមទឹកដី នៃភាគីនោះ ។

៣- ឯកសារណាមួយដែលគេបាន កំណត់ថាមិនមានសុពលភាពដោយអាជ្ញាធរ ឬ ភ្នាក់ងារទាំងឡាយមានការចាត់ តាំង នៃភាគីចុះកិច្ចសន្យានោះ ឬ ដោយជនណាម្នាក់ដែលទទួលការអនុញ្ញាត ឬ ផ្តល់អាជ្ញាប័ណ្ណដោយភាគី ចុះកិច្ចសន្យា ឬ ប្រែជាមិនមានសុពលភាព អនុលោមទៅតាមច្បាប់ទាំងឡាយ នៃភាគីចុះកិច្ចសន្យា ដែលបាន ចេញឯកសារ ឬ ការពន្យានោះមិនត្រូវបានគេទទួលស្គាល់សំរាប់អនុវត្តពិធីសានេះទេ ។

ពង្រាងបញ្ចប់លើកទី ១

៤- ឯកសារណាមួយប្រសិនជាមិនមែនសរសេរជាភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយនូវឯកសារបកប្រែបញ្ជាក់ជាភាសាអង់គ្លេសចេញដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

មាត្រាទី ៦
សញ្ញាគំនូសសំគាល់សមាជិក

យានយន្តដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោកមួយ ត្រូវបង្ហាញអោយឃើញនៅផ្នែកខាងក្រោយ នៃយានយន្ត នៅគ្រប់ពេលវេលាទាំងអស់ នៅពេលដែលស្ថិតនៅក្នុងទឹកដីនៃភាគីចុះកិច្ចសន្យាដទៃទៀត នូវផ្លាកសញ្ញាដែលអាចបិទភ្ជាប់បានទាំងឡាយដែលជាតំណាងអោយគ្រឿងសំគាល់ ដែលមានការទទួលស្គាល់និងការកំណត់ជាអន្តរជាតិ របស់ភាគីចុះកិច្ចសន្យាដែលយានយន្តត្រូវបានគេចុះបញ្ជីជាមួយ ។

មាត្រាទី ៧
ការរៀបចំស្ថាប័ន

១- កិច្ចប្រជុំរបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ាន ត្រូវតែជាអ្នកទទួលខុសត្រូវសំរាប់ការ ត្រួតពិនិត្យ តាមដានពិនិត្យមើលឡើងវិញ សំរបសំរួល និងត្រួតត្រាមើល នូវទិដ្ឋភាពទាំងអស់ពាក់ព័ន្ធទៅនឹងការប្រតិបត្តិដ៏មានប្រសិទ្ធិភាព នៃពិធីសារនេះ ។

២- កិច្ចប្រជុំរបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ាន ត្រូវដាក់ស្នើតាមរយៈលេខាធិការដ្ឋានអាស៊ាន របាយការណ៍ជាទៀងទាត់ នូវភាពជឿនលឿន នៃការប្រតិបត្តិពិធីសារនេះ ទៅក្រុមប្រឹក្សាកិបាលសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ ដែលបានបង្កើតឡើងអនុលោមទៅតាមមាត្រាទី 29.2 នៃកិច្ចព្រមព្រៀងសំរាប់សកម្មភាពនានាបន្ថែមទៀត ។

៣- លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់នូវការទ្រទ្រង់ និងជំនួយខាងបច្ចេកទេស ទៅដល់កិច្ចប្រជុំ របស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ អាស៊ាន ក្នុងមុខការ និងការទទួលខុសត្រូវរបស់គេ ដូចដែលមានចែងក្នុងពិធីសារនេះ ។

មាត្រាទី ៨
អទសានបញ្ញត្តិ

១- ពិធីសារនេះនឹងត្រូវបានគេតំកល់ទុកនៅអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយជាបន្ទាន់ នូវច្បាប់ចំលងមួយ ដែលមានបញ្ជាក់ដូចគ្នានេះ ទៅភាគីចុះកិច្ចសន្យាទាំងអស់ ។

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

២- ពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វានឹងបង្កើតឡើងបានជាផ្នែកមួយរួមបញ្ចូលគ្នាជាមួយកិច្ចព្រមព្រៀង

៣- ពិធីសារនេះ គឺជាកម្មវត្ថុក្នុងការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា លិខិតតុបករណ៍នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមត្រូវតែតំកល់ទុកនៅជាមួយនឹងអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់ពត៌មានយ៉ាងរហ័សទៅភាគី ចុះកិច្ចសន្យានិមួយៗ នូវការតំកល់ទុកនេះ ។

៤- ពិធីសារនេះនឹងត្រូវចូលជាធរមាននៅពេលណាដែលការតំកល់ទុកនូវលិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រម ធ្វើឡើងពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ នៅអគ្គលេខាធិការអាស៊ាន ។

៥- ការធ្វើវិសោធនកម្មណាមួយទៅលើប្រការទាំងឡាយ ដែលមានចែងក្នុងពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វាសំរេចទៅបានតាមរយៈការព្រមព្រៀងគ្នា ពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

ជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលសិទ្ធប្រទានយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេទាំងឡាយរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារទី ៤ ស្តីពីតម្រូវការបច្ចេកទេសយានយន្ត ដើម្បីអនុវត្តកិច្ចព្រមព្រៀង ស្តីពីការសំរួលទំនិញឆ្លងកាត់ ។

ធ្វើនៅ. ទីក្រុងហាណូយ. វៀតណាម នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ ជាច្បាប់ទោលតែមួយគត់ សរសេរជាភាសាអង់គ្លេស ។

....
PENIN DATO HAJI ZAKARIA SULAIMAN
រដ្ឋមន្ត្រីគមនាគមន៍
ប្រ៊ុយណេដារូសាឡាម

....
KHY TAINGLIM
រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន
ព្រះរាជាណាចក្រកម្ពុជា

....
ANWAR SUPRIJADI
អគ្គលេខាធិការ ក្រសួងគមនាគមន៍
សាធារណរដ្ឋឥណ្ឌូណេស៊ី

01/09/99 Protocol-3
ពង្រាងបញ្ចប់លើកទី ១

....
PHAO BOUNNAPHOL
រដ្ឋមន្ត្រីគមនាគមន៍, ដឹកជញ្ជូន, ប្រៃសណីយ៍ និងសំណង់
សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

....
DATO' SERI DR. LING LIONG SIK
រដ្ឋមន្ត្រីដឹកជញ្ជូន
ម៉ាឡេស៊ី

....
MAJ GEN HLA MYINT SWE
រដ្ឋមន្ត្រីដឹកជញ្ជូន
សហភាពមីយ៉ាន់ម៉ា

....
VICENTE C. RIVERA. JR.
រដ្ឋលេខាធិការ ដឹកជញ្ជូន និងគមនាគមន៍
សាធារណរដ្ឋហ្វីលីពីន

....
YEO CHEOW TONG
រដ្ឋមន្ត្រីគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន
សាធារណរដ្ឋសិង្ហបុរី

....
SUTHEP THAUGSUBAN
រដ្ឋមន្ត្រីដឹកជញ្ជូន និងគមនាគមន៍
ព្រះរាជាណាចក្រថៃឡង់ដ៍

....
LE NGOC HOAN
រដ្ឋមន្ត្រីដឹកជញ្ជូន
សាធារណរដ្ឋសង្គមនិយមវៀតណាម

PROTOCOL 4
TECHNICAL REQUIREMENTS OF VEHICLES

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, Lao People's Democratic Republic, Malaysia, Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Vietnam, Member States of the Association of Southeast Asian Nations (hereinafter referred to as "Contracting Parties");

RECALLING the ASEAN Framework Agreement on the Facilitation of Goods in Transit signed on 16 December 1998 in Hanoi, Vietnam (hereinafter referred to as "the Agreement");

RECOGNISING that Articles 11 and 25 of the Agreement provide for the conclusion of implementing Protocols which shall form integral parts thereof;

RECALLING further the Hanoi Plan of Action which was adopted by the Heads of State and Government of ASEAN at the Sixth ASEAN Summit in Hanoi, Vietnam on 16 December 1998 stipulates to operationalise the Agreement by the year 2000;

NOW, WHEREFORE, the Contracting Parties have agreed as follows:

Article 1
Definitions

For the purposes of this Protocol,

a) "Transit transport " shall have the meaning assigned to it in the Agreement;

b) "Road transit transport vehicle" shall have the meaning assigned to it in Protocol 3;

c) "Protocol 3" means Protocol 3 - Types and Quantity of Road Vehicles made pursuant to the Agreement;

d) "wheelbase" means the distance between the centre line of the first axle and the centre of the rear tandem axle of three axled rigid motor vehicle; and

e) "maximum permissible gross vehicle weight" means the maximum permissible weight of a wheeled vehicle, including the weight of its driver and any other person on board, and any load carried on it or by it, transmitted to the road at any given moment through all the wheels of the wheeled vehicle.

Article 2
Scope of Application

Pursuant to Article 11 of the Agreement, the Contracting Parties hereby agree to apply the provisions of this Protocol to road transit transport vehicles engaging in transit transport.

CERTIFIED COPY
SECRET...

Article 3
Obligations

1. The Contracting Parties shall ensure that each road transit transport vehicle shall be registered with the respective National Transit Transport Coordinating Committee (NTTCC) of which the transit transport operator is registered in compliance with Protocol 3.

2. The Contracting Parties shall ensure that each road transit transport vehicle complies with the technical requirements regarding vehicle dimensions, maximum weights and loads, emission standards and related matters as detailed in this Protocol.

Article 4
Mandatory Technical Requirements

1. The road transit transport vehicle to which this Protocol applies shall not be allowed to engage in transit transport unless the following technical requirements are fulfilled:

   a) Maximum Vehicle Dimensions, viz:
      - i) Maximum length of vehicle as detailed in Annexes A and B;
      - ii) Maximum width of vehicles as detailed in Annex C;
      - iii) Maximum height of vehicles as detailed in Annex D; and
      - iv) Rear overhang as detailed in Annex E.

   b) Maximum Permissible Gross Vehicle Weight as detailed in Annex F.

CERTIFIED COPY ASEAN SECRETARIAT

c) Emission Standards as follows:
Exhaust emission (smoke) - 50% (Opacity or Bosch unit) or 50 HSU; and

d) Other related requirements, viz:
   i) Brake Efficiency : 50% of the axle weight and
   ii) Side Slips: plus (+) or minus (-) 5 m/km.

3. The Contracting Parties hereby agree to standardise the above Technical Requirements for this Protocol but considering the present road conditions in some Contracting Parties, it was agreed that necessary arrangements be made to share updated information concerning designated roads periodically among Contracting Parties and accordingly use only suitable vehicle appropriate to those road conditions at the early stages of implementation of this Protocol. At the same time, the Contracting Parties hereby affirm their detemination to upgrade their designated road transit transport network with every possible efforts to accommodate vehicles with the above Technical Requirements.

Article 5
Documentation

1. The following documents shall be carried on a road transit transport vehicle at all times when it is in the territory of the relevant Contracting Party across whose territory the road transit transport vehicle passes:

   a) Motor Vehicle Registration Certificate containing the particulars of the vehicle and the owner;
   b) Valid Certificate of Inspection;
   c) Motor Vehicle Third Party Liability Insurance Cover;

d) Consignment Note/Waybill;

e) Custom Transit Document for the Goods; and

f) Carrier's Licence.

2. All documents as mentioned above shall be made available for inspection upon demand by the relevant authorities of the Contracting Parties across whose territory the transit transport vehicle passes.

3. Any document which is determined to be invalid by the designated authorities or agencies of the Contracting Party or by any person authorized or licensed by the Contracting Party, or is rendered invalid pursuant to the laws of the Contracting Party, which issued that document, or is expired, shall not be recognized for the purposes of this Agreement.

4 Any document if not drawn up in English shall be accompanied by a certified translation in English issued by the relevant competent authority.

Article 6

Distinguishing Marks

A road transit transport vehicle shall display at the rear of the vehicle, at all times when it is in the territory of another Contracting Party, detachable stickers representing the internationally recognised and designated insignia of the Contracting Party of which the vehicle is registered.

CERTIFIED COPY SECRETARY GENERAL OF ASEAN

Article 7
Institutional Arrangements

1 The ASEAN Senior Transport Officials Meeting shall be the responsible body for the monitoring, review, coordination and supervision of all aspects relating to the effective implementation of this Protocol.

2. The ASEAN Senior Transport Officials Meeting shall submit, through the ASEAN Secretariat, regular reports of the progress of implementation of this Protocol to the Transit Transport Coordinating Board, established pursuant to Article 29.2 of the Agreement, for further action.

3. The ASEAN Secretariat shall provide the necessary technical support and assistance to the ASEAN Senior Transport Officials Meeting in its functions and responsibilities under this Protocol.

Article 8
Final Provisions

1 This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Contracting Party.

2 This Protocol and its Annexes shall form an integral part of the Agreement.

3. This Protocol is subject to ratification or acceptance by the Contracting Parties. The Instrument of Ratification or Acceptance shall be deposited with the Secretary-General of ASEAN who shall promptly inform each Contracting Party of such deposit.

CERTIFIED COPY
SECRETARY GENERAL

4. This Protocol shall enter into force upon the deposit of Instruments of Ratification or Acceptance by all Contracting Parties with the Secretary-General of ASEAN.

5. Any amendment to the provisions of this Protocol and its Annexes shall be effected by consent of all the Contracting Parties.

IN WITNESS WHEREOF, the undersigned, being duly authorized to sign by their respective Governments, have signed Protocol 4 - Technical Requirements of Vehicles to implement the ASEAN Framework Agreement on the Facilitation of Goods in Transit.

DONE at Hanoi, Vietnam on the 15th day of September 1999, in a single copy in the English language

....
PEHIN DATO HAJI ZAKARIA SULAIMAN
Minister of Communications
Brunei Darussalam

....
KAN TAINGLIM
Minister of Public Works and Transport
Kingdom of Cambodia

....
ANWAR SUPRIJADI
Secretary General
Ministry of Communications
Republic of Indonesia

CERTIFIED COPY

....

PHAO BOUNNAPHOL
Minister of Communication, Transport, Post and Construction
Lao People's Democratic Republic

....

DATO' SERI DR. LING LIONG SIK
Minister of Transport
Malaysia

....

MAJ. GEN. HLA MYINT SWE
Minister of Transport
Union of Myanmar

....

VICENTE C. RIVERA, JR.
Secretary of Transportation and Communications
Republic of the Philippines

....

YEO CHEOW TONG
Minister for Communications and Information Technology
Republic of Singapore

CERTIFIED COPY
SECRETARY-GENERAL

....
SUTHEP THAUGSUBAN
Minister of Transport and Communications
Kingdom of Thailand

....
LE NGOC HOAN
Minister of Transport
Socialist Republic of Vietnam

CERTIFIED COPY

Annex A

MAXIMUM LENGTH OF VEHICLE



RIGID MOTOR VEHICLE

CERTIFIED COPY

Annex B

MAXIMUM LENGTH OF VEHICLE



ARTICULATED VEHICLE

MAXIMUM WIDTH OF VEHICLE

Annex C



ALL VEHICLES

CERTIFIED COPY

MAXIMUM HEIGHT OF VEHICLE

Annex D



ALL VEHICLE

REAR OVERHANG (ROH)

Annex E

THREE AXLE RIGID MOTOR VEHICLE



CERTIFIED COPY
SECRE

TYPE OF VECHICLE	MAXIMUM PERMISSIBLE GROSS VEHICLE WEIGHT (Tonnes)
	21.0 T
	25.0 T
	32.0 T
	36.0 T
	38.0 T

SECRETARY GENERAL OF ASEAN CERTIFIED COPY

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ

និង ដឹកជញ្ជូន

លេខៈ 1084 សក

រាជធានីភ្នំពេញ, ថ្ងៃទី 23 ខែ 6 ឆ្នាំ 2005

សូមគោរពជូន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កម្មវត្ថុ : សំណើសុំពិនិត្យសំរេច និងសុំសច្ចាប័នជាថ្មីពីសភាជាតិលើពិធីសារអាស៊ានចំនួន ០២ ។

យោង : - លិខិតលេខ ៩២៩ លសកបច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

- សិទ្ធិប្រទានលេខ ៤៣ សប្រទ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩ កន្លងទៅ នៅក្នុងកិច្ចប្រជុំលើកទី ៥ រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន នៅទីក្រុងហាណូយ ប្រទេសវៀតណាម ក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះហត្ថលេខាលើពិធីសារចំនួន ០២ ដូចខាងក្រោម សំរាប់អនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ :

១- ពិធីសារទី ៣ : ស្តីពីការកំណត់ប្រភេទ និងបរិមាណរថយន្តដឹកជញ្ជូនឆ្លងកាត់

២- ពិធីសារទី ៤ : ស្តីពីតំរូវការបច្ចេកទេសរបស់រថយន្តដឹកជញ្ជូនឆ្លងកាត់

សូមជំរាបជូនថា ពិធីសារទាំងពីរនេះត្រូវបានសភាជាតិនិតិកាលទី២ ពិនិត្យ និងអនុម័តម្តងរួចហើយ និង បានបញ្ជូនទៅព្រឹទ្ធសភា ដើម្បីពិនិត្យ អនុម័តកាលពីឆ្នាំ ២០០២-២០០៣ កន្លងទៅ ។ ប៉ុន្តែពិធីសារទាំងពីរ ត្រូវបានសភាជាតិនិតិកាលទី ៣ បញ្ជូនមករាជរដ្ឋាភិបាលវិញ និងស្នើអោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិនិត្យ និង ស្នើសុំការអនុម័តពីសភាជាតិជាថ្មីឡើងវិញ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាពិនិត្យសំរេច និងស្នើសុំទៅសភាជាតិជាថ្មី ដើម្បីផ្តល់សច្ចាប័ន លើពិធីសារខាងលើនេះ តាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

រដ្ឋមន្ត្រីស្តីទី

ស្ងួន ហោង

ចំលងជូន

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តមរដ្ឋលេខាធិការ-អនុរដ្ឋលេខាធិការ
- ឯកឧត្តម អគ្គនាយក
- ឯកសារ-កាលប្បវត្តិ

មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ-ទូរសារ : (៨៥៥) ២៣ ៤២៦ ៦៤០ , (៨៥៥) ២៣ ៤២៧ ៨៦២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ .សព/បទ

M.P.W.T
ចូល IN លេខ 5180
ថ្ងៃទី 14 SEP. 1999

សិទ្ធិប្រទាន

_រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម ឃី តាំងលីម រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីពិភាក្សា និងចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាលើ :

_ពិធីសារទី ១ : ស្តីពីការកំណត់ផ្លូវ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់

_ពិធីសារទី ៣ : ស្តីពីការកំណត់ប្រភេទ និងបរិមាណរថយន្តដឹកជញ្ជូនឆ្លងកាត់

_ពិធីសារទី ៤ : ស្តីពីតម្រូវការបច្ចេកទេសរបស់រថយន្តដឹកជញ្ជូនឆ្លងកាត់

_កិច្ចព្រមព្រៀងថ្នាក់រដ្ឋមន្ត្រី ស្តីពីការអភិវឌ្ឍន៍បណ្តាញផ្លូវអាស៊ានហាយវេ ជាមួយប្រទេសជាសមាជិកអាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៥ និង ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

រាជរដ្ឋាភិបាល កម្ពុជា

Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

Nº 43 DFP

DELEGATION OF FULL POWER

The Royal Government of Cambodia delegates herewith to H. E. Mr. KHY TAINGLIM, Minister of Public Works and Transport, the full powers to negociate and sign the following documents with the ASEAN member governments :

-Protocol 1: On the Designation of Road Transit Transport Routes and Facilities

-Protocol 3: On Types and Quantity of Road Vehicles

-Protocol 4: On Technical Requirement of Road Vehicles

-Ministerial Understanding on the Development of the ASEAN Highway Network Projet.

In witness wherof, the undersigned, the Acting Prime Minister of the Kingdom of Cambodia, with full powers duly entrusted to him, has signed this full power.

Phnom Penh, 13 September 1999

SAR KHENG

Acting Prime Minister

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៨១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ឡុង កែម ជា អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : តែងតាំងលោកជំទាវ នួត បញ្ញា ជា ទីប្រឹក្សា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០២.០៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ ១០១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ០២ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន រិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគូបមជាតិសាសនា វរក្សត្រិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក **ឈី ហួរ**

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៧០២.០៩២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខៈ ៩៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានត្ថមិជាតិសាសនា រតនខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេច ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង :

១- ឯកឧត្តម **ឌុយ គី** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម **សាយ បូរិន** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- ឯកឧត្តម **កែប ពិសិដ្ឋ** ជាទីប្រឹក្សាផ្ទាល់សម្តេចប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ.ល.០៧០២.០៩៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខៈ ១០០ ច.ល
[illegible]
... ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ចំនួន ២នាក់នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ទោ

-លោកឧត្តមសេនីយ៍ត្រី ប្រុក សារឿន អត្តលេខ ០១៤១

ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី

-លោកវរសេនីយ៍ឯក តាន់ ចាយ អត្តលេខ ០៤០៨

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០២.០៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៧

លេខៈ ១១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៨៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
